# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីភារកិច្ចរបស់ម្ដាយឪពុកនិងកូន

Website: www.hoksavann.org

ថ្ងៃទី១៦ តុលា ២០០៤

១- អំពីភារកិច្ចរបស់ម្ដាយឪពុកខ្មែរនៅបរទេស ៖

ដោយព្រឹត្តិការណ៍ប្រែប្រួលនៃប្រទេសកម្ពុជា បានជម្រុញឲ្យជនជាតិខ្មែរខ្លះ មកតាំងទីលំនៅឆ្ងាយពីមាតុប្រទេសរបស់ខ្លួននៅបរទេសដូចជាសហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលីជាដើម ។ ដូច្នេះឪពុកម្ដាយត្រូវមានភារកិច្ចថ្មីមួយទៀត ក្នុងការអប់រំកូនចៅនៅលើទឹកដីថ្មី ។ ភារកិច្ចជាចំបងគឺជំរុញកូនឲ្យខំសិក្សារៀនសូត្រ ឲ្យមានចំណេះចេះដឹងកំរិតខ្ពស់ ព្រោះមត៌កដែលម្ដាយឪពុកចែកឲ្យកូននៅទីនេះ គឺចំណេះវិជ្ជានេះឯង ។ ជាមួយគ្នានឹងការជំរុញកូនឲ្យរៀន ត្រូវណែនាំអប់រំកូនឲ្យមានចរិយាល្អ ស្របតាមប្រពៃណីទំនៀមទំលាប់សណ្ដាប់ធ្នាប់ដ៏ល្អរបស់ជាតិខ្លួនគឺជាតិខ្មែរ ។ បានសេចក្ដីថា កូនចៅបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះវិជ្ជា ពីសាលារដ្ឋរបស់គេហើយ មិនត្រូវបំភ្លេចចោលវប្បធម៌របស់ជាតិខ្លួនឡើយ ។ គប្បីជំរុញកូនឲ្យនិយាយភាសាខ្មែរនៅក្នុងគ្រួសារ ហើយលៃពេលឲ្យកូនរៀនអក្សរខ្មែរផង ។ ពេលត្រឡប់មកពីធ្វើការវិញឆ្លៀតពេលនិយាយពន្យល់កូនអំពីប្រវត្តិសាស្ត្រនិងភូមិសាស្ត្រខ្មែរ ព្រមទាំងទំនៀមទំលាប់ដ៏ល្អរបស់ខ្មែរ ដើម្បីឲ្យកូននៅទីនោះដឹងច្បាស់លាស់ និងយល់ចូលចិត្តអំពីវប្បធម៌របស់ជាតិខ្លួន ។ គប្បីនាំកូនទៅវត្ត ដើម្បីឲ្យព្រះសង្ឃជួយពន្យល់ណែនាំកូន អំពីតម្លៃនៃវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិ ។

វត្តពុទ្ធសាសនាខ្មែរជាមជ្ឈដ្ឋានសំខាន់ក្នុងការអប់រំកូនចៅខ្មែរតាំងបីសម័យបូរាណមក តាមមាគ៌ារបស់ព្រះពុទ្ធជាម្ចាស់ ជាមាគ៌ាដ៏ល្អបរិសុទ្ធដែលធ្វើឲ្យមនុស្សមានជីវិតថ្លៃថ្នូរ ។ ពិសេសកូនបានទទួលឱវាទពីព្រះសង្ឃអំពីព្រះធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ។

ក្រៅពីនិស្ស័យវាសនាកូនដែលបានទាក់ទងពីបុព្វជាតិមក ម្ដាយឪពុកក៏ត្រូវតែទទួលខុសត្រូវចំពោះវាសនាកូនទៅមុខទៀត ដែលទាក់ទងនឹងការអប់រំ ព្រោះការអប់រំជាគោលសំខាន់ កំរឹតវាសនាកូនក្នុងបច្ចុប្បន្ននេះនិងទៅអនាគត ។ ម្ដាយឪពុកណាដែលមិនចង់ឲ្យកូនចេះនិយាយខ្មែរ ចេះអក្សរខ្មែរ ចេះដឹងវប្បធម៌ខ្មែរ ជាកំហុសធំណាស់ចំពោះកូនទៅអនាគត ដែលម្ដាយឪពុកត្រូវទទួលខុសត្រូវ ចំពោះការបំបាត់វប្បធម៌ជាតិខ្លួននេះ ។ នៅប្រទេសភូមា ប្រទេសសេរីលង្កា និងប្រទេសថៃ រៀងរាល់ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ ម្ដាយឪពុកបាននាំកូនមកកាន់ទីវត្ត ដើម្បីឲ្យព្រះសង្ឃអប់រំសីលធម៌ព្រះពុទ្ធសាសនា មានឲ្យសមាទានសីល៥ រហូតបង្ហាត់ឲ្យអង្គុយធ្វើសមាធិទៀតផង ។ ផ្ទុយទៅវិញ ម្ដាយឪពុកខ្មែរខ្លះនៅបរទេស នៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ បែរជានាំកូនទៅដើរលេងនិងទុកឱកាសឲ្យសាសនាដទៃមកបញ្ចុះបញ្ចូល ឲ្យទៅកាន់សាសនាគេ ។ នៅពេលដែលកូនដើរផ្លូវខុស មិនស្ដាប់ដំបូន្មានខ្លួនអំពីរឿងគូស្រករ ដោយសារតែទទួលវប្បធម៌បរទេស មិនធ្វើតាមទំនៀមទំលាប់ខ្លួន ទើបម្ដាយឪពុកខ្លះនឹកស្ដាយក្រោយ ប៉ុន្តែវាហួសពេលទៅហើយ ។

២- អំពីភារកិច្ចរបស់កូនប្រុសស្រីនៅបរទេស ៖

តាមធម្មតា កូនប្រុសស្រីនៅក្នុងបឋមវ័យគឺវ័យនៅក្មេង ម្ដាយឪពុកឬអាណាព្យាបាលតែងតែបញ្ជូនឲ្យទៅសិក្សា ។ ភារកិច្ចរបស់កូនដែលជាសិស្ស គឺការខំប្រឹងប្រែងសិក្សារៀនសូត្រ និងធ្វើកិច្ចការដែលគ្រូដាក់ឲ្យ ។ ក្រៅពីនោះ កូនប្រុសស្រីត្រូវមានចរិយាមារយាទថ្លៃថ្នូរ កុំរត់ចោលសាលា ត្រូវរៀនឲ្យមានវិជ្ជាខ្ពង់ខ្ពស់ កុំដើរលេងសប្បាយ រហូតភ្លេចការសិក្សា ។ កូនប្រុសស្រីមានភ័ព្វសំណាងណាស់ ដែលបានមករស់នៅប្រទេសដែលសម្បូណ៌ការសិក្សា ដូច្នេះកុំឲ្យពេលវេលាកន្លងទៅ ដោយពុំមានការសិក្សា ត្រូវដើរទន្ទឹមគ្នានឹងការលូតលាស់នៃពិភពលោក ជាពិសេសបែប្រទេសដែលកូនចៅប្រុសស្រីកំពុងរស់នៅនេះ ។ ថ្ងៃក្រោយ បើកូនចៅប្រុសស្រីមានបំណងចង់ទៅជួយកសាងមាតុប្រទេសវិញ ក៏មានលទ្ធភាពជួយបាន ព្រោះមានសមត្ថភាពគ្រប់គ្រាន់ ។

ប្រទេសកម្ពុជាពីដើម ការអប់រំកូនចៅមានការងាយស្រួលជាងនៅបរទេស ព្រោះជាប្រទេសកំណើតរបស់ខ្លួន ហើយរដ្ឋាភិបាលក៏ជារដ្ឋាភិបាលខ្មែរ ឯកម្មវិធីសិក្សានៅក្នុងសាលា ក៏តម្រូវទៅតាមប្រពៃណីទំនៀមទំលាប់ខ្មែរ និងស្របតាមមុខវិជ្ជាទូទៅ ដែលគ្រប់ប្រទេសក្នុងពិភពលោកលើកយកមកសិក្សា ។ កូនចៅខ្មែរសិក្សាជាច្រើនម៉ោងនៅសាលារដ្ឋលុះត្រឡប់មកវិញ ម្ដាយឪពុកពុំសូវមានពេលទំនេរ ដើម្បីពន្យល់កូនចៅឲ្យស្គាល់ជាតិខ្លួន វប្បធម៌ជាតិខ្លួនឡើយ ព្រោះរវល់ធ្វើការ ។ ដូច្នេះកូនចៅខ្មែរបានទទួលវប្បធម៌ពីរ គឺវប្បធម៌របស់ជាតិខ្លួនផង និងវប្បធម៌របស់ប្រទេសដែលខ្លួនស្នាក់នៅផង ថ្ងៃក្រោយអាចមានទំនាស់ជាមួយឪពុកម្ដាយអំពីទស្សនៈនិងការអនុវត្តន៍ខុសគ្នានេះ ។ កូនចៅប្រុសស្រីគប្បីគិតថា ម្ដាយឪពុកខ្លះ ទោះបីគាត់មានចំណេះវិជ្ជាតិចតួចជាងកូនសម័យនេះក៏ដោយ ក៏គាត់មានការពិសោធន៍ច្រើននៅក្នុងបញ្ហាជីវិតដែរ ដូច្នេះកូនប្រុសស្រីត្រូវយកយោបល់គាត់មកពិចារណា ផ្សំនឹងចំណេះវិជ្ជារបស់ខ្លួនដែលបានសិក្សាផង ដើម្បីឲ្យផែនការជីវិតប្រព្រឹត្តទៅបានសុខចំរើន ។

ច្បាប់នៅសហរដ្ឋអាមេរិកនិងប្រទេសកាណាដា កូនប្រុសស្រីដែលមានអាយុ១៨ឆ្នាំឡើងទៅ អាចរើសគូស្រករដោយខ្លួនឯងបាន រីឯទំនៀមទំលាប់ខ្មែរ ទោះបីកូនមានអាយុលើសពី១៨ឆ្នាំក៏ដោយ ការសំរេចឲ្យមានគូស្រករ ក៏បន្ទុកនៅលើឪពុកម្ដាយ រួមជាមួយយោបល់ផ្ទាល់របស់កូនផង ។ ដូច្នេះកូនប្រុសស្រីខ្មែរនៅបរទេស គួររក្សាប្រពៃណីនេះ ដោយសម្របសម្រួលបញ្ហារើសគូស្រករនេះជាមួយឪពុកម្ដាយ កុំសំរេចតាមតែទំនើងចិត្តខ្លួនឯង ។ ម្ដាយឪពុកគួរស្ដាប់ពាក្យកូនដែលមានយោបល់ល្អ ឯកូនប្រុសស្រីក៏គប្បីស្ដាប់បង្គាប់គាត់ បើគាត់ណែនាំទៅរកផ្លូវល្អហើយ ។ ម្ដាយឪពុកជាអ្នកមានគុណ កូនមិនត្រូវមានគំនិតថា ខ្លួនមានចំណេះវិជ្ជាសម័យថ្មីហើយ មើលងាយឪពុកម្ដាយរបស់ខ្លួនឡើយ ព្រោះវិជ្ជាថ្មីក៏កើតពីគំនិតចាស់ ដែលបានត្រួសត្រាយផ្លូវដែរ ។ កូនដែលស្ថិតនៅក្នុងបឋមវ័យកំពុងសិក្សា ពុំទាន់មានការពិសោធន៍ក្នុងបញ្ហាជីវិតនៅឡើយ បើមានបញ្ហាណាមួយកើតឡើង គប្បីយកបញ្ហានោះពិគ្រោះជាមួយឪពុកម្ដាយ ដើម្បីចៀសវាងការវិនិច្ឆ័យខុស ។ មួយទៀត ការប្រើមនោសញ្ចេតនាតាមយុវវ័យ ឆាប់អរឆាប់សប្បាយឆាប់រំភើបឆាប់ខឹង ក៏នាំឲ្យវិនិច្ឆ័យនិងសំរេចចិត្តខុសដែរ ។ កុំអាលបន្ទោសមនុស្សជំនាន់ចាស់ៗថាធ្វើខុស ដោយពុំបានប្រមូលហេតុផល និងភស្តុតាងច្បាស់លាស់

ព្រោះជួនកាល សិស្សនិងនិស្សិតចេះវិជ្ជាតាមតែសៀវភៅ តាមតែទ្រឹស្ដី មើលឃើញការងារនោះងាយ លុះដល់អនុវត្តទើបដឹងច្បាស់ថា ការងារនោះពិបាក ហើយជួនកាលអនុវត្តពុំកើតផង មានការងារខ្លះអនុវត្តពុំកើតត្រូវតែកែទ្រឹស្ដីវិញផង ។ ម្យ៉ាងទៀត សិស្សនិងនិស្សិតដែលបានសិក្សាវិជ្ជាបរទេស មុននឹងយកទៅអនុវត្តនៅប្រទេសខ្មែរ ចាំបាច់ត្រូវតែសិក្សាលក្ខណៈខ្មែរឲ្យច្បាស់លាស់ជាមុនសិន គឺត្រូវឆ្លៃរចនាលក្ខណៈគេឲ្យទៅជាលក្ខណៈខ្មែរ ព្រោះមានវិជ្ជាខ្លះអាចអនុវត្តបានជោគជ័យតែកន្លែងមួយពុំបានជោគជ័យកន្លែងមួយទៀតក៏មាន គឺត្រូវសិក្សាថា ប្រទេសកម្ពុជាមានទឹកដីធាតុអាកាស និងទឹកចិត្តខ្មែរមានលក្ខណៈបែបណា ដែលអាចយកវិជ្ជានោះទៅអនុវត្តបានជោគជ័យ ។ ដូចជាការយកលទ្ធិកុម្មុយនិស្តខ្មែរក្រហមទៅអនុវត្តនៅប្រទេសកម្ពុជាកន្លងមកនេះ ដែលជាលទ្ធិផ្ទុយពីទឹកចិត្តខ្មែរ បានធ្វើឲ្យប្រទេសកម្ពុជាវិនាសអន្តរាយ ។

ទីបំផុតនេះ សូមអំពាវនាវព្រះអង្គចៅអធិការគ្រប់វត្តនៅក្រៅប្រទេស ដូចនៅសហរដ្ឋអាមេរិក កាណាដា បារាំង និងអូស្ត្រាលីជាដើម សូមចាត់ចែងឲ្យមានការបង្រៀនអក្សរខ្មែរនិងសីលធម៌ព្រះពុទ្ធសាសនាដល់កូនចៅខ្មែរគ្រប់វត្ត ដើម្បីរួមវិភាគទានក្នុងការរក្សាប្រពៃណីនិងវប្បធម៌ខ្មែរឲ្យបានគង់វង់ ហើយឲ្យវប្បធម៌ទាំងនោះស្ថិតនៅក្នុងសន្ដានចិត្តនៃកូនចៅខ្មែរគ្រប់ៗគ្នានៅបរទេស ។ សប្បុរសរបស់ព្រះសង្ឃក្នុងការជួយអប់រំកូនចៅខ្មែរ ចាត់ទុកថាជាវិភាគទានដ៏ឧត្តុងឧត្តមពុំអាចកាត់ថ្លៃបាន ។ ចំណែកម្ដាយឪពុកឬអាណាព្យាបាលរបស់កូនចៅខ្មែរ គួរយកចិត្តទុកដាក់ធ្វើសហការជាមួយព្រះសង្ឃ ដោយបញ្ជូនកូនចៅឲ្យទៅសិក្សាអក្សរខ្មែរនិងសីលធម៌ព្រះពុទ្ធសាសនានៅទីវត្ត តាមកម្មវិធីរបស់វត្តនីមួយៗ ។ សង្ឃឹមថា ព្រះសង្ឃនិងជនជាតិខ្មែរនៅបរទេស មិនបំភ្លេចចោលនូវសេចក្ដីអំពាវនាវនេះឡើយ ។៚